**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០២*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**ចម្លងជូន :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣ "ដើម្បីអនុវត្ត"*
- *ឯកសារ កាលប្បវត្តិ* ✓

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ៣៥៣ អនក្រ.បក

## អនុក្រឹត្យ

### ស្តីពីការជូនមេដាយស្ថាបនាជាតិ

&&&&&

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

### សំ រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជនជប៉ុន ០៣ ក្រុម ដែលបានធ្វើអំណោយជាអគារសិក្សា តុ កៅអី បង្គន់ និង សម្ភារៈកីឡាផ្សេងៗ ជូនសាលាបឋមសិក្សាត្រពាំងក្រឡឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ដូចមានខាងក្រោម ÷

១- FUNABASHI SAZANKA LIONS CLUB ថវិកា ២០.០០០ USD
២- CHIBA PORT LIONS CLUB ថវិកា ២០.០០០ USD
៣- PHNOM PENH OBAYKHOM LIONS CLUB ថវិកា ២០.០០០ USD

**មាត្រា ២ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា និងអភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៣៥៤ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

&&&&&

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

## ស ំ រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជនជប៉ុន ០៣ រូប ជាតំណាងអង្គការ CESS ដែលបានធ្វើអំណោយជាអគារសិក្សា និង ផ្ទះសំណាក់ សំរាប់គ្រូស្ម័គ្រចិត្តជប៉ុន នៅស្រុកព្រះស្តេច ខេត្តព្រៃវែង ចំណាយអស់ទឹកប្រាក់ចំនួន ៥៦.៤០០ USD ដូចមានខាងក្រោម ÷

១- លោក KAZUYUKI TSUTSUMI , CESS Chairman

២- លោកស្រី YUKO KOUMOTO , CESS Vice Chairwoman

៣- លោកស្រី YUKIKO MATSUO , CESS General Secretary

**មាត្រា ២ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា និងអភិបាលខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ:...៧៥៥...អនក្រ.បក

## អនុក្រឹត្យ

### ស្តីពីការជូនមេដាយសហមេត្រី

& & & & &

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អគ្គមេបញ្ជាការ កងយោធពលខេមរភូមិន្ទ

### ស ម្រេ ច

**មាត្រា ១:** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **សេនា** ជូន **សកលវិទ្យាល័យវិទ្យាសាស្ត្រនិងវិស្វកម្ម** នៃកងទ័ពរំដោះប្រជាជនចិន ( **NANJING Science and Engineering University of P.L.A** ) ដែលបានជួយកសាង កងយោធពលខេមរភូមិន្ទ តាំងពីឆ្នាំ ២០០០ រហូតមកដល់បច្ចុប្បន្ន ទទួលបានលទ្ធផលល្អប្រសើរ ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ និងអគ្គមេបញ្ជាការ កងយោធពលខេមរភូមិន្ទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែ កក្កដា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ -កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៣៥៦ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងនាយនគរបាលជាតិជាន់ខ្ពស់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤/ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៥០១ / ១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥០ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីការកែសម្រួលរចនាសម្ព័ន្ធ និង ប្តូរឈ្មោះខុទ្ទកាល័យក្រសួងមហាផ្ទៃមកជាអគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា ១** : ត្រូវបានតែងតាំងមុខតំណែងនាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម :

១-លោកឧត្តមសេនីយ៍ទោ **ខៀវ សុភគ៌** អត្តលេខ ០០៧២ បច្ចុប្បន្ន នាយការងខុទ្ទកាល័យ នៃក្រសួងមហាផ្ទៃ មកជាអគ្គលេខាធិការរង នៃ អគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ ។

២-លោកឧត្តមសេនីយ៍ត្រី **មាស សាខុន** អត្តលេខ ០៣១២ បច្ចុប្បន្ន នាយការងខុទ្ទកាល័យ នៃក្រសួងមហាផ្ទៃ មកជាអគ្គលេខាធិការរង នៃ អគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ ។

**មាត្រា ២** : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយ នឹង អនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ចម្លងជូន :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៧៤៧ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ស ម្រេ ច

**មាត្រា១** : ត្រូវបានតម្លើងឋានន្តរសក្តិថ្នាក់ **វរសេនីយ៍ឯក** ជូននាយនគរបាលជាតិនៃក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម :

១-លោកវរសេនីយ៍ទោ **ជា ពៅ** អត្តលេខ ០២២០២ ជំនួយការឯកឧត្តមរដ្ឋលេខាធិការស្នងការនគរបាលជាតិ ។

២-លោកវរសេនីយ៍ទោ **គី សុជិន** អត្តលេខ ០៧៨២ អនុប្រធានមន្ទីរប្រឆាំងគ្រឿងញៀន ។

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី២២ ខែ កក្កដា ឆ្នាំ២០០២*

**នាយករដ្ឋមន្ត្រី**

ហ៊ុន សែន

*កន្លែងទទួល :*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៣៥៨ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការតែងតាំងសមាសភាពតំណាងទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងក្រុមប្រឹក្សាភិបាលមន្ទីរពេទ្យកាល់ម៉ែត

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៦/៩៤ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៦ ស្តីពីការដាក់មន្ទីរពេទ្យកាល់ម៉ែត ជាគ្រឹះ ស្ថានសាធារណៈរដ្ឋបាល
- យោងតាមសំណើរបស់ប្រធានក្រុមប្រឹក្សាភិបាលមន្ទីរពេទ្យកាល់ម៉ែត

**សំរេច**

**មាត្រា ១ៈ** ត្រូវបានតែងតាំងលោក **ខឹម ទិសិដ្ឋ** ប្រធាននាយកដ្ឋានអប់រំ វប្បធម៌ សង្គមកិច្ច នៃទីស្តីការគណៈរដ្ឋមន្ត្រីជា **សមាជិកក្រុមប្រឹក្សាភិបាលមន្ទីរពេទ្យកាល់ម៉ែត** ជាថ្មីម្តងទៀត ។

**មាត្រា២ៈ** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសារធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធនិងសាម៉ីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**ចំលងជូន**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣៥៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាល នៃសាលាភូមិន្ទចៅក្រម

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តិនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ០៩ អនក្រ.បក ចុះថ្ងៃទី ០៥ ខែកុម្ភៈ ឆ្នាំ ២០០២ ស្តីពីការបង្កើតសាលាភូមិន្ទចៅក្រម
- តាមសំណើរបស់ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សំរេច

**មាត្រា ១ :**

តែងតាំងសមាសភាពក្រុមប្រឹក្សាភិបាលនៃសាលាភូមិន្ទចៅក្រម ដូចមានរាយនាមខាងក្រោមៈ

១- ឯកឧត្តម សុខ អាន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធាន

| | | | | | |
|---|---|---|---|---|---|
| ២- | ឯកឧត្តម | **នាថ** | **ស៊ីថុន** | រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | អនុប្រធាន |
| ៣- | លោកជំទាវ | **គិម** | **សត្ថាវី** | នាយិកាសាលាភូមិន្ទចៅក្រម | សមាជិកពេញសិទ្ធិ |
| ៤- | ឯកឧត្តម | **សំ** | **សុដល** | អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់<br>តំណាងក្រុមប្រឹក្សាអ្នកច្បាប់ | សមាជិក |
| ៥- | លោកជំទាវ | **លី** | **វុចឡេង** | ប្រធានសាលាឧទ្ធរណ៍<br>តំណាងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម | សមាជិក |
| ៦- | ឯកឧត្តម | **ក្រាញ់** | **ជ័យឈាតី គូនី** | សមាជិកក្រុមប្រឹក្សាអ្នកច្បាប់<br>តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៧- | ឯកឧត្តម | **ជួន** | **ស៊ុនឡេង** | អគ្គព្រះរាជអាជ្ញាស្តីទី អមតុលាការកំពូល | សមាជិក |
| ៨- | ឯកឧត្តម | **យូ** | **ម៉ិនឡេង** | ចៅក្រមសាលាឧទ្ធរណ៍ | សមាជិក |
| ៩- | លោកស្រី | **ស៊ីវ** | **គិមស៊ាន** | អនុប្រធាននាយកដ្ឋាននីតិកម្ម<br>តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១០- | ចៅក្រមបារាំង ជំនាញការនាយក | | | | សមាជិកអញ្ជើញ |
| ១១- | នាយកការសិក្សាសាលា | | | | សមាជិកអញ្ជើញ។ |

**មាត្រា ២ :**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័នពាក់ព័ន្ធ សាលាភូមិន្ទចៅក្រម និងសាមីខ្លួន ដែលមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣៨ សសរ

# សេចក្តីសំរេច

## ស្តីពី

## ការបង្កើតគណៈកម្មការដើម្បីអនុវត្តសេចក្តីជូនដំណឹង

## លេខ ១០០៤ សជណ.អរ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០២

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណូមពរការងារចាំបាច់

## សំរេច

**ប្រការ ១** : បង្កើតគណៈកម្មការមួយដើម្បីអនុវត្តសេចក្តីជូនដំណឹងលេខ ១០០៤ សជណ.អរ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០២ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីអំពីការអនុញ្ញាតជាគោលការណ៍អោយនិស្សិតដែលមានសញ្ញាប័ត្រមកពីជំរុំបានបន្តការសិក្សានៅតាមគ្រឹះស្ថានឧត្តមសិក្សា ក្នុងព្រះរាជាណាចក្រកម្ពុជា ។

គណៈកម្មការនេះ មានសមាសភាព ដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១_ឯកឧត្តម | សុខ អាន | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២_ឯកឧត្តម | ម៉ុក ឌន | រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និង កីឡា | អនុប្រធាន |
| ៣_ឯកឧត្តម | អ៊ឹម សិទ្ធី | រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និង កីឡា | អនុប្រធាន |
| ៤_ឯកឧត្តម | ព្រំ សុខា | រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | សមាជិក |

៥_ឯកឧត្តម ស៊ាន ប៊ូរ៉ាត ទីប្រឹក្សាផ្ទាល់សម្ដេចនាយករដ្ឋមន្ត្រី សមាជិក

៦_ឯកឧត្តម ពេជ សោភ័ន អគ្គនាយកនៃអគ្គនាយកដ្ឋានឧត្ដមសិក្សាបច្ចេកទេស និង វិជ្ជាជីវៈ សមាជិក

៧_លោក ខៀវ ថាវិភា ប្រធាននាយកដ្ឋានពត៌មាន ទីស្ដីការគណៈរដ្ឋមន្ត្រី សមាជិក

៨_លោក ខឹម ទិសិដ្ឋ ប្រធាននាយកដ្ឋានអប់រំ ទីស្ដីការគណៈរដ្ឋមន្ត្រី សមាជិក

៩_លោក រ័ត្ន សុខា ប្រធាននាយកដ្ឋានឧត្ដមសិក្សា លេខាធិការ

**ប្រការ ២ :** គណៈកម្មការនេះមានភារកិច្ច ៖

_ពិភាក្សា និង លើកវិធានការត្រួតពិនិត្យផ្ទៀងផ្ទាត់លើសន្លឹកសញ្ញាប័ត្ររបស់និស្សិតដែលមកពីជំរុំ អោយបានត្រឹមត្រូវ ។

_ពិនិត្យ និង សំរេចលើសំណើសុំបន្តការសិក្សានៅតាមគ្រឹះស្ថានឧត្ដមសិក្សារបស់និស្សិតដែលមានសញ្ញាប័ត្រមកពីជំរុំពិតប្រាកដ ។

_រាយការណ៍អំពីលទ្ធផលការងារជូនរាជរដ្ឋាភិបាល ។

**ប្រការ ៣ :** សមាជិកគណៈកម្មការនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។ ប្រធានគណៈកម្មការអាចបង្កើតអនុគណៈកម្មការជាជំនួយការតាមការចាំបាច់ ។

**ប្រការ ៤ :** គណៈកម្មការនេះ ត្រូវរំសាយជាស្វ័យប្រវត្តិនៅពេលបានបំពេញភារកិច្ចចប់ជាស្ថាពរ ។

**ប្រការ ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងឯកឧត្តម អស់លោក ដែលមានចែងក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសំរេចនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០០២*

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៥*
- *ឯកសារ_កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...៣៩...សសរ

# សេចក្តីសំរេច

## ស្តីពី

## ការបង្កើតក្រុមការងារដើម្បីទ្រទ្រង់ និងសំរបសំរួលដល់ការរៀបចំប្រគុំតន្ត្រីសប្បុរសធម៌ (Charity Concert) និងការរៀបចំទិវាបង្ហាញម៉ូដសំលៀកបំពាក់ (Fashion Show) នៅខេត្តសៀមរាប

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ ១.-**

ត្រូវបានបង្កើតក្រុមការងារដើម្បីទ្រទ្រង់ និងសំរបសំរួលដល់ការរៀបចំប្រគុំតន្ត្រីសប្បុរសធម៌ (Charity Concert) និងការរៀបចំទិវាបង្ហាញម៉ូតសំលៀកបំពាក់ (Fashion Show) នៅខេត្តសៀមរាប ដែលមានសមាសភាពដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | ថោង ខុន | រដ្ឋលេខាធិការ ក្រសួងទេសចរណ៍ | ប្រធាន |
| ២-ឯកឧត្តម | ស៊ឹម សួន | ទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី ទទួលការងារទេសចរណ៍ | អនុប្រធាន |
| ៣-ឯកឧត្តម | ឌេត ហែន | អគ្គនាយករងអាជ្ញាធរអប្សរា | អនុប្រធាន |

| | | | |
|---|---|---|---|
| ៤- លោក | សួស យ៉ារ៉ា | អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិទេសចរណ៍កម្ពុជា | សមាជិកប្រចាំការ |
| ៥-ឯកឧត្តម | រស់ រ៉េន | អនុរដ្ឋលេខាធិការ ក្រសួងទេសចរណ៍ | សមាជិក |
| ៦-ឯកឧត្តម | ឌា សុត្ថា | អនុរដ្ឋលេខាធិការ រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល | សមាជិក |
| ៧-ឯកឧត្តម | ហង្ស សុត | អគ្គនាយក ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ៨-ឯកឧត្តម | ឧត្តមសេនីយ៍ឯក តេង សាវង្សអគ្គនាយករងអគ្គស្នងការដ្ឋាននគរបាលជាតិក្រសួងមហាផ្ទៃ | | សមាជិក |
| ៩-ឯកឧត្តម | ជា សុខុម | អគ្គលេខាធិការរងគណៈកម្មាធិការអចិន្ត្រៃរៀបចំបុណ្យជាតិនិងអន្តរជាតិ | សមាជិក |
| ១០-លោក | ចាន់ សុផល | អភិបាលរងខេត្តសៀមរាប | សមាជិក |
| ១១-លោក | ឡាយ ម្ជុនី | នាយករងទីចាត់ការគយ និងរដ្ឋាករ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១២-លោក | ង៉ាក់ សុខុម | ប្រធាននាយកដ្ឋានសិក្សាទីផ្សារ និងផ្សព្វផ្សាយ ក្រសួងទេសចរណ៍ | សមាជិក |
| ១៣-លោក | ឆាយ ថៃ | អនុប្រធាននាយកដ្ឋាន អាជ្ញាធរជាតិទេសចរណ៍កម្ពុជា | សមាជិក |

**ប្រការ ២.-**

ក្រុមការងារនេះមានភារកិច្ចដូចខាងក្រោម:

- រៀបចំទីតាំងសម្តែងសិល្បៈ ទស្សនីយភាព
- រៀបចំទទួលភ្ញៀវជាតិ និងអន្តរជាតិ
- រៀបចំសន្តិសុខ និងសណ្តាប់ធ្នាប់
- សំរួលដល់ការហោះហើរ
- ការងារទាក់ទងទៅនឹងបែបបទចេញ-ចូល ផ្នែកទិដ្ឋាការ ផ្នែកគយ និងការងារផ្សេងៗទៀតទាក់ទងនឹងការធ្វើដំណើរ
- បូកសរុប រាយការណ៍ អំពីលទ្ធផលជូនប្រមុខរាជរដ្ឋាភិបាល

**ប្រការ ៣.-**

ការចំណាយក្នុងការរៀបចំទស្សនីយភាពសិល្បៈ ហូបចុក ដឹកជញ្ជូន ជាបន្ទុកទទួលខុសត្រូវរបស់ក្រុមហ៊ុន :

- Rafles Holding & Rafles International Limited
- Chosun ilbo times founder, Bang, eung-mo.Foundation association.

**ប្រការ ៤.-**

ក្រុមការងារមានសិទ្ធិបង្កើតអនុគណៈកម្មការតាមការចាំបាច់។

**ប្រការ ៥.-**

សមាជិកក្រុមការងារ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុមការងារ។

**ប្រការ ៦.-**

ក្រុមការងារនេះត្រូវចប់ភារៈកិច្ច និងត្រូវរំសាយជាស្វ័យប្រវត្តិនៅពេលចប់ទិវាទាំងពីរ។

**ប្រការ ៧ .** ~

ក្នុងការបំពេញភារៈកិច្ចរបស់ខ្លួន ក្រុមការងារមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងទេសចរណ៍ ។

**ប្រការ ៨ .** ~

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានអគ្គនាយកអាជ្ញាធរអប្សរា ប្រធានអាជ្ញាធរជាតិទេសចរណ៍កម្ពុជា ប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ និងអន្តរជាតិ រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកទីចាត់ការគយ និងរដ្ឋាករ សាលាខេត្តសៀមរាប ក្រសួង ស្ថាប័ន អាជ្ញាធរពាក់ព័ន្ធ ព្រមទាំងឯកឧត្តម អស់លោក ដែលមានឈ្មោះក្នុងក្រុមការងារត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កក្កដា ឆ្នាំ ២០០២

**ហ៊ុន សែន**

<u>**ចំលងជូន**</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទការល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១០. សរណន

# សារាចរណែនាំ

## ស្តីពី

## ការរៀបចំពិធីបុណ្យកាន់បិណ្ឌ-ភ្ជុំបិណ្ឌ និងកឋិនទាន

✳ បុណ្យកាន់បិណ្ឌ-ភ្ជុំបិណ្ឌ ជាបុណ្យប្រពៃណីជាតិដ៏សំខាន់របស់ពុទ្ធបរិស័ទខ្មែរគ្រប់រូប ។ ពិធីនេះប្រារព្ធឡើង ដើម្បីឧទ្ទិសកុសលជូនដល់វិញ្ញាណក្ខ័ន្ធនៃអ្នកមានគុណទាំងឡាយ មានមាតាបិតា ជីដូនជីតា គ្រូឧបជ្ឈាយាចារ្យ បុព្វបុរសជាតិ និងបងប្អូនជនរួមជាតិទាំងឡាយ ដែលបានលាចាកលោកនេះទៅកាន់លោកខាងមុខ ។ ម្យ៉ាងទៀត ពិធីនេះ ក៏ជាឱកាសជួបជុំឪពុក ម្តាយ បងប្អូនញាតិមិត្ត សាច់សាលោហិត ដែលរស់នៅទីផ្សេងៗគ្នា និងអាចស្វែងយល់បានពីសុខទុក្ខ និង ដំណើរប្រព្រឹត្តទៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃរវាងគ្នានិងគ្នា ទៅវិញទៅមក ព្រមទាំងអាចបង្កើនបាននូវសាមគ្គីភាពដ៏ទូលំទូលាយផង ។

ឆ្នាំនេះ ពិធីបុណ្យកាន់បិណ្ឌ-ភ្ជុំបិណ្ឌ នឹងប្រព្រឹត្តទៅពីថ្ងៃ ១រោច ដល់ថ្ងៃ ១៥រោច ខែ ភទ្របទ ត្រូវនឹង ថ្ងៃទី ២២ ខែ កញ្ញា ដល់ថ្ងៃទី ៦ ខែ តុលា ឆ្នាំ ២០០២ ។

✳ បុណ្យកឋិនទាន ជាកាលទានមួយដ៏ថ្លៃថ្លា មានលក្ខណៈពិសេសនៅក្នុងព្រះពុទ្ធសាសនា ដែលក្នុងមួយឆ្នាំមានតែម្តង មានរយៈពេលកំណត់តែ ២៩ ថ្ងៃ វត្តមួយទទួលបានតែអង្គកឋិនមួយ ជាទានមានផលានិសង្សខ្ពស់ ទាំងទាយកទាយិកាអ្នកឱ្យ និងទាំងបដិគ្គាហកៈអ្នកទទួល ជាទីជ្រះថ្លា និងចំណូលចិត្តរបស់ពុទ្ធបរិស័ទខ្មែរ ដែលតែងតែប្រារព្ធធ្វើរៀងរាល់ឆ្នាំ ។ ក្រៅពីនេះ តាមរយៈកឋិនទាន វត្តនិមួយៗក៏មានលទ្ធភាពអាចនឹងទទួលបាននូវសម្ភារៈ ថវិកាយ៉ាងច្រើន បំរើការកសាងទីសេនាសនៈនៅក្នុងវត្ត មានព្រះវិហារ កុដិ សាលា និងជួយឧបត្ថម្ភដល់ការកសាងសមិទ្ធផលសង្គម និងវិស័យសង្គមកិច្ច ផងថែមទៀត ។

ឆ្នាំនេះ កឋិនទាន នឹងត្រូវប្រព្រឹត្តទៅពីថ្ងៃ ១រោច ខែ អស្សុជ ដល់ថ្ងៃ ១៥ កើត ខែ កត្តិក ត្រូវនឹងថ្ងៃទី ២២ ខែ តុលា ដល់ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០២ ។

ដើម្បីបើកឱកាសប្រគេនព្រះសង្ឃ ជូនពុទ្ធបរិស័ទបំពេញកុសលតាមសទ្ធាជ្រះថ្លា ជូនបុត្តធីតា បងប្អូន សិស្សានុសិស្ស មានលទ្ធភាពធ្វើបដិការៈគោរពតបស្នងសងគុណ មាតាបិតា ជីដូនជីតា អាណាព្យាបាល គ្រូឧបជ្ឈាយាចារ្យ តាមជំនឿនិងបានរួមចំណែកថែរក្សានូវប្រពៃណីទំនៀមទម្លាប់និងអត្តសញ្ញាណជាតិ ឱ្យបានគង់វង្ស រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សូមធ្វើការណែនាំដូចតទៅនេះ :

១- គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និងគ្រប់ខេត្ត-ក្រុង ត្រូវផ្សព្វផ្សាយអំពីខ្លឹមសារពិធីបុណ្យទាំងពីរខាងលើ ឱ្យបានជ្រួតជ្រាបទូលំទូលាយ និងបំផុសលើកទឹកចិត្ត បង្កលក្ខណៈងាយស្រួល ឱ្យមន្ត្រីរាជការ

ក្នុងឱវាទជាពុទ្ធសាសនិក បានចូលរួមបំពេញបុណ្យកុសល ជាប្រពៃណី នៅតាមវត្តអារាម ឬនៅក្នុងអង្គភាពរបស់ខ្លួន ព្រមទាំងបានជួបជុំឪពុក ម្ដាយ បងប្អូន ជីដូន ជីតា តាមបំណងប្រាថ្នា ។

២- ក្រសួងធម្មការនិងសាសនា ត្រូវធ្វើការណែនាំលំអិតដល់មន្ទីរធម្មការ និងសាសនាខេត្ត-ក្រុង យកចិត្តទុកដាក់បង្កលក្ខណៈឱ្យបានល្អប្រសើរ ប្រគេនព្រះសង្ឃ ជូនពុទ្ធបរិស័ទ ប្រារព្ធពិធីកាន់បិណ្ឌ-ភ្ជុំបិណ្ឌ និងបុណ្យកឋិនទាន តាមប្រពៃណីព្រះពុទ្ធសាសនា និងទំនៀមទម្លាប់ជាតិ ដោយសទ្ធាជ្រះថ្លា តាមពេលវេលាកំណត់ ។

គ្រប់វត្តអារាម ត្រូវរៀបចំបោសសំអាតបូជនីយដ្ឋាន ស្តូប កន្លែងតម្កល់អដ្ឋិធាតុ បងប្អូនជនរួមជាតិ ដែលបានបាត់បង់ជីវិតក្នុងរបបប្រល័យពូជសាសន៍ និងរៀបចំបង្សុកូល ឧទ្ទិសកុសលជូនដល់វិញ្ញាណក្ខ័ន្ធ បុព្វបុរស ដែលបានពលីក្នុងបុព្វហេតុជាតិមាតុភូមិ និងជនរួមជាតិយើងទាំងនោះ តាមប្រពៃណីព្រះពុទ្ធសាសនា ។

រាល់ផលទាន ដែលកើតឡើងដោយពិធីបុណ្យទាំងពីរខាងលើ មានម្ហូបអាហារ នំចំណីជាដើម គប្បីរំលែកចែកជូនដល់បងប្អូនក្រីក្រ បងប្អូនពិការ កុមារកំព្រា តាមលទ្ធភាពរបស់វត្តនិមួយៗ ជាពិសេស សម្ភារៈ ថវិកា ត្រូវណែនាំឱ្យមានការគ្រប់គ្រង និងប្រើប្រាស់ឱ្យបានគត់មត់ សមហេតុផល ជៀសវាងការបាត់បង់ដោយប្រការផ្សេងៗ និងបង្កឱ្យមានទៅជាទំនាស់បែកបាក់សាមគ្គី ដែលនឹងអាចកើតមានជាយថាហេតុ ។

គ្រប់អ្នកផ្តួចផ្តើមដង្ហែអង្គកឋិន ត្រូវត្រួតពិនិត្យមើលឱ្យបានគ្រប់ជ្រុងជ្រោយ នូវប្រភេទក្មេងស្ទាវ ដែលចូលរួមដង្ហែអង្គកឋិន ព្រោះអាចមានមនុស្សមិនសុចរិត បង្កសកម្មភាព អាចនាំឱ្យមានទំនាស់រវាងក្រុមមួយទៅក្រុមមួយ ធ្វើឱ្យខូចតម្លៃនៃបុណ្យកឋិនទាន ។

៣- អាជ្ញាធរគ្រប់ថ្នាក់ ត្រូវធ្វើការណែនាំ និងអប់រំយុវជន យុវនារី កុមារា កុមារី ដែលចូលរួមដង្ហែអង្គកឋិន ឱ្យយល់ពីតម្លៃនៃពិធីបុណ្យដ៏ឧត្តុង្គឧត្តមនេះ ហើយចេះធ្វើខ្លួនឱ្យស័ក្តិសមជាកូនចៅរបស់ពុទ្ធសាសនិកពិតប្រាកដ ដោយមិនបង្កសកម្មភាពនាំឱ្យប៉ះពាល់ដល់កិត្តិយសព្រះពុទ្ធសាសនា ដូចជាការគប់ស្បោងទឹក ជះទឹក គប់អំពៅ គប់ផ្លែឈើ និងគប់ដោយវត្ថុរឹងផ្សេងៗ ធ្វើឱ្យខូចរបៀបរៀបរយ សណ្តាប់ធ្នាប់សង្គម និងអាចឈានទៅរកគ្រោះថ្នាក់ដោយអំពើលេងសើចគ្មានរបៀបនេះ ។

៤- ក្រសួងពត៌មាន ត្រូវណែនាំឱ្យបណ្តាញឃោសនា វិទ្យុ ទូរទស្សន៍ជាតិ ឯកជន អ្នកយកពត៌មាន តាមដានស្វែងយល់ ស្រាវជ្រាវប្រវត្តិខ្លឹមសារ និងសកម្មភាពនៃពិធីបុណ្យប្រពៃណី និងអំពីរបៀបរបបស្លៀកពាក់ ក៏ដូចជាអាកប្បកិរិយា ឫកពា សុភាពរាបសារ ដែលត្រូវប្រកាន់យកក្នុងពេលចូលរួមពិធីបុណ្យប្រពៃណីនេះ នៅក្នុងវត្តអារាម ផ្សព្វផ្សាយឱ្យបានទូលំទូលាយ ។

៥- ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ ត្រូវណែនាំដល់អង្គភាពក្រោមឱវាទ ឱ្យសហការការពារសន្តិសុខ របៀបរៀបរយសណ្តាប់ធ្នាប់សង្គម បង្កលក្ខណៈ ប្រគេនព្រះសង្ឃ ជូនពុទ្ធបរិស័ទ បំពេញបុណ្យកុសល តាមជំនឿ និងធានាសុវត្ថិភាព សប្បាយរីករាយ ។

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សង្ឃឹមថា ថ្នាក់ដឹកនាំគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័នពាក់ព័ន្ធ និងគ្រប់ខេត្ត-ក្រុង និងចាត់តាំងអនុវត្តស្មារតីសារាចរណែនាំនេះ ឱ្យបានសម្រេច លទ្ធផលល្អប្រសើរ ស្របតាមប្រពៃណីជាតិដ៏រុងរឿងរបស់យើង ។

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និងគ្រប់ខេត្ត-ក្រុង
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១១......សរ.ណន

# សារាចរណែនាំ

## ស្តីពី

## ការរៀបចំព្រះរាជពិធីបុណ្យខួបលើកទី ៩ នៃការគ្រងរាជសម្បត្តិជាថ្មី របស់ ព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងទិវាប្រកាសរដ្ឋធម្មនុញ្ញ

✳ ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០០២ គឺជាទិវាបុណ្យខួបលើកទី ៩ នៃការគ្រងរាជសម្បត្តិជាថ្មី របស់ **ព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ** ព្រះមហាក្សត្រជាទីសក្ការៈ និងទិវាប្រកាសរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។ គឺថ្ងៃនេះហើយ ដែលប្រជារាស្ត្រខ្មែរគ្រប់រូប បានសំដែងឆន្ទៈ និងមនោសញ្ចេតនា របស់ខ្លួនសប្បាយរីករាយយ៉ាងជ្រាលជ្រៅបំផុត ចំពោះ**ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង** ដែលសព្វព្រះរាជហឫទ័យ ទ្រង់គ្រងរាជសម្បត្តិជាថ្មីឡើងវិញ ដើម្បីបានគង់នៅជាម្លប់ដ៏សុខក្សេមក្សាន្តត្រជាក់ត្រជុំរបស់មាតុភូមិ អង្គរ និងប្រជារាស្ត្រខ្មែរ ជាកូន ជាចៅ ចៅទួតរបស់ព្រះអង្គ ។

✳ ថ្ងៃទី ២៤ ខែ កញ្ញា នេះដែរ ក៏ជាថ្ងៃដែលរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ជាច្បាប់កំពូល ប្រកបដោយខ្លឹមសារយ៉ាងជ្រាលជ្រៅលើគ្រប់វិស័យដែលសភាធម្មនុញ្ញបានអនុម័ត ត្រូវបានប្រកាសដ៏មហោឡារិក បើកអោយប្រើប្រាស់ជាផ្លូវការក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា ដើម្បីធ្វើឱ្យប្រជារាស្ត្រខ្មែរ ពង្រឹងបានសាមគ្គីភាព ឯកភាពជាតិរឹងមាំ រក្សាការពារបូរណភាពទឹកដី ប្រជាធិបតេយ្យថ្លៃថ្លា និងអរិយធម៌អង្គរដ៏បវរ កសាងប្រទេសជាតិ មានសុខសន្តិភាព និងទទួលខុសត្រូវខ្ពស់ចំពោះជោគវាសនាអនាគតជាតិ ដើម្បីអភិវឌ្ឍន៍ឈានឡើង និងសំបូររុងរឿង ។

ដើម្បីសំដែងនូវកតញ្ញូតាធម៌ និងថ្វាយព្រះពរសព្ទសាធុការ បវរមហាប្រសើរចំពោះ **ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង** និង **សម្តេចព្រះរាជអគ្គមហេសី** ជាទីសក្ការៈ ដែលទ្រង់ប្រកបដោយព្រះមហាករុណាទិគុណ និងព្រហ្មវិហារធម៌ដ៏ថ្លៃថ្លា សូមទ្រង់គង់នៅក្នុងព្រះបរមសិរីរាជសម្បត្តិយូរអង្វែង សំដែងនូវអំណរសាទរ គោរពដោយស្មោះត្រង់ ចំពោះរដ្ឋធម្មនុញ្ញ រាជរដ្ឋាភិបាលកម្ពុជា សូមធ្វើការណែនាំអនុវត្តដូចតទៅ :

១-គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និងគ្រប់ខេត្ត-ក្រុង ត្រូវតុបតែងលំអរចនាដោយភ្លើងពណ៌ តាំងព្រះឆាយាល័ក្ខណ៍ **ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង** និង **សម្តេចព្រះរាជអគ្គមហេសី** ដោយមានពាក្យស្លោក ថ្វាយព្រះពរ និងសារលិខិតថ្វាយព្រះពរ តាមស្ថាប័ន អង្គភាពរបស់ខ្លួន ព្រមទាំងបំផុសប្រជារាស្ត្រ អោយដោតទង់ជាតិ គ្រប់គេហដ្ឋាន និងបដាអបអរសាទរ តាមពាក្យស្លោកដូចជូនភ្ជាប់ជាមួយនេះ ។

២-គ្រប់ខេត្ត-ក្រុង ត្រូវចាត់តាំងរៀបចំពិធីបុណ្យទាំងពីរខាងលើ អោយបានសមស្របតាមលទ្ធភាពជាក់ស្តែង ក្នុងក្របខ័ណ្ឌខេត្ត-ក្រុងនីមួយៗ ដោយមានព្រះសង្ឃក្នុងក្របខ័ណ្ឌខេត្ត-ក្រុង ថ្នាក់ដឹកនាំខេត្ត-ក្រុង មន្ត្រីរាជការនៃមន្ទីរនានា ជុំវិញខេត្ត-ក្រុង ខ័ណ្ឌ-ស្រុក អ្នកមុខអ្នកការ ប្រជាពលរដ្ឋចូលរួមអោយបានឧឡារិក ព្រមទាំងមានកម្មវិធីចុះសួរសុខទុក្ខតាមមន្ទីរពេទ្យ មណ្ឌលកុមារកំព្រាផង ។

៣-ក្រសួងពត៌មាន ត្រូវណែនាំចាត់អោយបណ្តាញវិទ្យុ ទូរទស្សន៍ជាតិ និងឯកជនតាមដានយកពត៌មាន ធ្វើការផលិត ផ្សព្វផ្សាយ ឃោសនា នូវព្រះរាជសកម្មភាព និងស្នាព្រះហស្ត **ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង** និងខ្លឹមសារនៃរដ្ឋធម្មនុញ្ញ ។

៤-ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវធ្វើការណែនាំដល់មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត-ក្រុង ចាត់តាំងក្រុមតន្ត្រីសិល្បៈបុរាណ សម័យ សំដែងជូនប្រជារាស្ត្រទស្សនាកំសាន្តសប្បាយ នៅតាមទីសាធារណៈ ដើម្បីចូលរួមអបអរសាទរក្នុងទិវា ជាប្រវត្តិសាស្ត្រនេះ នៅថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០០២ ។

៥-ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ ត្រូវណែនាំដល់អង្គភាព ក្រោមឱវាទអោយសហការ ការពារសន្តិសុខ របៀបរៀបរយ សណ្តាប់ធ្នាប់សង្គម បំរើការរៀបចំពិធីបុណ្យគ្រងរាជសម្បត្តិជាថ្មីរបស់ព្រះមហាក្សត្រ និងទិវាប្រកាសរដ្ឋធម្មនុញ្ញ ឱ្យធានាបានសុវត្ថិភាព និងសប្បាយរីករាយ ។

៦-គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ ត្រូវមានផែនការបែងចែកតាមក្រសួង រដ្ឋលេខាធិការដ្ឋាន មន្ទីរ ស្ថាប័ន អំពាវនាវសប្បុរសជន អង្គការក្រៅរដ្ឋាភិបាល, អង្គការមនុស្សធម៌ ក្រុមហ៊ុនឯកជន ជួយឧបត្ថម្ភជាថវិកា សម្ភារៈ គ្រឿងឧបភោគ បរិភោគផ្សេងៗ ចុះសួរសុខទុក្ខដល់អ្នករបួស មានជម្ងឺកំពុងសម្រាកព្យាបាលនៅតាមមន្ទីរពេទ្យ, យុទ្ធជនពិការតាមមណ្ឌលពិការ កុមារកំព្រា ចាស់ព្រឹទ្ធាចារ្យគ្មានទីពឹង ដើម្បីសំដែងមនោសញ្ចេតនាអាណិតស្រឡាញ់រាប់អាន លើកទឹកចិត្ត និងជួយគ្នាទៅវិញទៅមក ។

រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា សង្ឃឹមថា ថ្នាក់ដឹកនាំគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័នពាក់ព័ន្ធ និងគ្រប់ខេត្ត-ក្រុង ចាត់តាំងអនុវត្តតាមស្មារតីនៃសារាចរណែនាំនេះ ឱ្យបានសំរេចលទ្ធផលល្អប្រសើរ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន
និងគ្រប់ខេត្ត-ក្រុង
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៨៤/០២ សហវ/វសហ

# សេចក្តីជូនដំណឹង

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានកិត្តិយសជំរាបជូនដំណឹងដល់មន្ត្រីរាជការនៃក្រសួងសាមី និង ក្រសួង/ស្ថាប័ននៃរាជរដ្ឋាភិបាលជ្រាបថា ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានតំរូវការជ្រើសរើសមន្ត្រីរាជការ ដើម្បីបណ្តុះបណ្តាលជំនាញ" ពន្ធដារ " នៅវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សំរាប់បំរើការងារក្នុងនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ចំនួន ៨៥ រូប ។

មន្ត្រីរាជការ ដែលមានបំណងចូលរៀន ដើម្បីធ្វើការក្នុងនាយកដ្ឋាននេះ នឹងត្រូវជ្រើសរើស តាមរយៈការប្រលងប្រជែង និង ដោយមានកាយសម្បទាមាំមួន និងមានលក្ខណៈសម្បត្តិដូចតទៅៈ

១. មានសញ្ញាប័ត្របរិញ្ញាប័ត្រឡើងទៅ ផ្នែកដែលពាក់ព័ន្ធសេដ្ឋកិច្ច ហិរញ្ញវត្ថុ ឬ ច្បាប់

២. មានចំណេះដឹងផ្នែកភាសាអង់គ្លេស និង បច្ចេកវិទ្យាព័ត៌មាន (មុខវិជ្ជាដែលត្រូវប្រលង)

៣. មានចំណេះដឹងទូទៅក្នុងផ្នែកសេដ្ឋកិច្ច ហិរញ្ញវត្ថុ និង គណនេយ្យ (មុខវិជ្ជាដែលត្រូវប្រលង)

៤. មានអាយុមិនលើស ៣៥ ឆ្នាំ ។

បេក្ខជនទាំងពីរភេទ ដែលមានក្របខ័ណ្ឌមកពីក្រសួង/ស្ថាប័នផ្សេង ត្រូវមានការយល់ស្របផ្ទេរក្របខ័ណ្ឌពីក្រសួង/ស្ថាប័នរបស់ខ្លួនជាមុន សំរាប់មកបំពេញការងារក្នុងក្របខ័ណ្ឌនៃនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ ការផ្ទេរក្របខ័ណ្ឌជាក់ស្តែង នឹងត្រូវធ្វើឡើងបន្ទាប់ពីបានបញ្ចប់ការសិក្សានៅវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាស្ថាពរ ។

សេចក្តីដូចបានជំរាបជូនខាងលើ ប្រសិនបើ មន្ត្រីរាជការនៃក្រសួងសាមី និងក្រសួង/ស្ថាប័ននៃរាជ-រដ្ឋាភិបាល មានបំណងចូលរួមការប្រលងនេះ សូមអញ្ជើញមកដាក់ពាក្យ និង បំពេញបែបបទនៅវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បន្ទប់លេខ ២៧ ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ រហូតដល់ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០២ ។ មន្ត្រីរាជការ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដូចរៀបរាប់ខាងលើ នឹងត្រូវបានអញ្ជើញមកចូលរួមប្រលង ដើម្បីជ្រើសរើសចូលរៀន ។ កម្មវិធី កាលបរិច្ឆេទនៃការប្រលង និងបញ្ជីរាយនាមបេក្ខជនដែលត្រូវប្រលង នឹងបិទផ្សាយជូននៅវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០២

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
No. ១៩៤ MoC / M 2002

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០០២

# ប្រកាស

## ស្តីពី ស្ថានភាពរោងចក្រមួយចំនួនក្នុងកម្ពុជា

*****

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យ លេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ ក្រសួងពាណិជ្ជកម្ម
- បានឃើញការចាំបាច់របស់ក្រសួង

## សំរេច

**ប្រការ ១** : ចាត់ទុករោងចក្រកាត់ដេរសំលៀកបំពាក់ខាងក្រោមដែលបានបិទទ្វារបណ្តោះអាសន្ន តាមប្រកាសលេខ ១៦០ MOC / M 2002 ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០២ ត្រង់ប្រការ ១ នោះបច្ចុប្បន្នត្រូវបានដំណើរការផលិតកម្ម និង ធ្វើនិយាតកម្ម ឡើងវិញធម្មតា ៖

**1- Honey Wear Garment Co., Ltd**
**2- Kong Kong Garment Co., Ltd.**

**ប្រការ ២ :** នាយកខុទ្ទកាល័យ , អគ្គនាយកបច្ចេកទេស , ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម , ប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស , ប្រធាននាយកដ្ឋាននីតិកម្ម និង រោងចក្រដែលមានឈ្មោះក្នុងប្រការ ១ ត្រូវអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ចម ប្រសិទ្ធ

**ចម្លងជូន :**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល
- ក្រសួងសង្គមកិច្ច-ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវៈនិតិសម្បទា
- ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំទីក្រុងប៉ារីស
- ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំទីក្រុងវ៉ាស៊ីនតោនឌីស៊ី
- ស្ថានទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា
- គណៈប្រតិភូសហគមន៍អឺរ៉ុបប្រចាំទីក្រុងបាងកក
- គណៈប្រតិភូសហគមន៍អឺរ៉ុបប្រចាំទីក្រុងភ្នំពេញ
- សមាគមកាត់ដេរសំលៀកបំពាក់នៅកម្ពុជា
- ឯកសារ-កាលប្បវត្តិ



Ministry of Commerce # 20 A & B Preah Norodom Boulevard, Phnom Penh 12205 ( Kingdom of Cambodia )
Minister' s Mobile Phone (855-12) 821888 Facsimile: (855-23) 213288
Staff's Mobile Phones: (855-12) 818883 / 881223 Facsimile: (855-23) 426396

# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**KINGDOM OF CAMBODIA**

Nation - Religion - King

ក្រសួងពាណិជ្ជកម្ម

Ministry of Commerce

No. ១៥៦ MoC / M 2002

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០២

## ប្រកាស
## ស្តីពី
## ការផ្អាកមិនផ្តល់វិក័យប័ត្រពាណិជ្ជកម្ម
## ដល់រោងចក្រកាត់ដេរសំលៀកបំពាក់ចំនួន ៣

*****

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្ត ទៅរបស់ គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យ លេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្ត ទៅរបស់ ក្រសួងពាណិជ្ជកម្ម
- បានឃើញលិខិតចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០២ របស់ស្ថានទូតសហរដ្ឋអាមេរិកប្រចាំព្រះរាជាណាចក្រកម្ពុជា
- បានឃើញការចាំបាច់របស់ក្រសួង

## សំរេច

<u>ប្រការ</u> ១ : ក្រសួងពាណិជ្ជកម្ម ផ្អាកការចេញវិក័យប័ត្រពាណិជ្ជកម្មដល់ក្រុមហ៊ុន ចំនួន ០៣ ដូចខាងក្រោមនេះ ដែលមិនបានសហការណ៍ជាមួយក្រុមត្រួតពិនិត្យផ្នែកផលិតកម្មវាយនភ័ណ្ឌរបស់គយសហរដ្ឋអាមេរិករហូត មានបទបញ្ជាជាថ្មី ÷

**1- Horus Industrial Corporation**
**2- G.T. Garment (Cambodia) Co., Ltd.**
**3- Kao Sing Ltd.**

<u>ប្រការ</u> ២ : ការចុះធ្វើអធិការកិច្ចបន្ថែមជាពិសេសមួយ ធ្វើឡើងដោយក្រសួងពាណិជ្ជកម្មចំពោះរោងចក្រទាំង ៣ នេះ ត្រូវអនុវត្តជាបន្ទាន់លើបណ្តាចំណុចដូចតទៅ :

- ត្រួតពិនិត្យឯកសារផលិតកម្ម ក្នុងឆ្នាំ ២០០០ និង ២០០១
- ជំរុញការស្រាវជ្រាវរកឯកសារទាំងឡាយ ដែលក្រុមការងារត្រួតពិនិត្យរបស់គយសហរដ្ឋអាមេរិកផ្នែកផលិតកម្មសំលៀកបំពាក់ត្រូវការនោះឱ្យបានឆាប់រហ័ស

<u>ប្រការ</u> ៣ : នាយកខុទ្ទកាល័យ , អគ្គនាយកបច្ចេកទេស , ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម , ប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស , ប្រធាននាយកដ្ឋានកាំកុងត្រូល , ប្រធានសមាគមកាត់ដេរសំលៀកបំពាក់នៅកម្ពុជា និង ប្រធានក្រុមហ៊ុនទាំង ៣ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធភាព ។

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

<u>**ចម្លងជូន**</u> :

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល
- ក្រសួងសង្គមកិច្ច-ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវៈនិតិសម្បទា
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ស្ថានរាជទូតកម្ពុជាប្រចាំទីក្រុងវ៉ាស៊ីនតោនឌីស៊ី
- ស្ថានទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា
- គ្រប់រោងចក្រកាត់ដេរសំលៀកបំពាក់នៅកម្ពុជា
- ដូចក្នុងប្រការ ៣
- ឯកសារ-កាលប្បវត្តិ

File: Prakas on imposing ban of the issuance of C/I to 3 garment factories in Cambodia

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
No. ២៥៧ MoC / M 2002

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០២

# ប្រកាស
## ស្តីពី
## ការព្រមានពេលចក្រកាត់ដេរសំលៀកបំពាក់ចំនួន ៣

*****

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្ត ទៅរបស់ គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យ លេខ ៥៤ អនក្របក ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្ត ទៅរបស់ ក្រសួងពាណិជ្ជកម្ម
- បានឃើញលិខិតចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០២ របស់ស្ថានទូតសហរដ្ឋអាមេរិកប្រចាំព្រះរាជាណាចក្រកម្ពុជា
- បានឃើញការចាំបាច់របស់ក្រសួង

## សំរេច

**ប្រការ ១ :** ក្រសួងពាណិជ្ជកម្ម ធ្វើការព្រមានរោងចក្រកាត់ដេរសំលៀកបំពាក់ចំនួន ០៣ ដូចខាងក្រោមនេះ ដែលសហការការងារស្រាវជ្រាវមិនបានល្អប្រសើរ និង ផ្តល់ឯកសារមិនគ្រប់គ្រាន់ជូនក្រុមត្រួតពិនិត្យផ្នែកផលិតកម្មវាយនភ័ណ្ឌរបស់គយសហរដ្ឋអាមិរិក ÷

1- **South Bay Enterprise**
2- **Kun Mao Hsing (Cambodia) Co., Ltd.**
3- **You Cheng Garment Co., Ltd.**

**ប្រការ ២ :** ក្រុមហ៊ុនទាំង ៣ ខាងលើត្រូវស្រាវជ្រាវរកឯកសារដែលក្រុមត្រួតពិនិត្យផ្នែកផលិតកម្មវាយនភ័ណ្ឌរបស់គយសហរដ្ឋអាមេរិកត្រូវការនោះឱ្យបានគ្រប់គ្រាន់ និង ត្រឹមត្រូវ ដើម្បីបញ្ជូនទៅគយសហរដ្ឋអាមេរិកអោយបានឆាប់រហ័សបំផុត ។

**ប្រការ ៣ :** ក្រសួងពាណិជ្ជកម្មនឹងមានវិធានការណ៍ដ៏តឹងរ៉ឹង ដោយអាចផ្អាកការចេញវិក័យប័ត្រពាណិជ្ជកម្មដល់ក្រុមហ៊ុនទាំងនេះ ប្រសិនបើក្រុមហ៊ុនមិនបានបង្ហាញនូវភាពច្បាស់លាស់របស់ខ្លួនកន្លងមក និង អនាគត ដើម្បីបំបាត់ភាពសង្ស័យក្នុងដំណើរការផលិតកម្ម និង នាំចេញ ។

**ប្រការ ៤ :** នាយកខុទ្ទកាល័យ , អគ្គនាយកបច្ចេកទេស , ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម , ប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស , ប្រធាននាយកដ្ឋានកាំកុងត្រូល , ប្រធានសមាគមកាត់ដេរសំលៀកបំពាក់នៅកម្ពុជា និង ប្រធានក្រុមហ៊ុនទាំង ៣ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធភាព ។

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

**ចម្លងជូន :**
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល
- ក្រសួងសង្គមកិច្ច-ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវៈនិតិសម្បទា
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ស្ថានរាជទូតកម្ពុជាប្រចាំទីក្រុងវ៉ាស៊ីនតោនឌីស៊ី
- ស្ថានទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា
- គ្រប់រោងចក្រកាត់ដេរសំលៀកបំពាក់នៅកម្ពុជា
- ដូចក្នុងប្រការ ៣
- ឯកសារ-កាលប្បវត្តិ

File: Prakas on warning 3 garment factories in Cambodia

Ministry of Commerce # 20 A & B Preah Norodom Boulevard, Phnom Penh 12205 ( Kingdom of Cambodia )
Minister' s Mobile Phone (855-12) 821888 Facsimile: (855-23) 213288
Staff's Mobile Phones: (855-12) 818883 / 881223 Facsimile: (855-23) 426396

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
លេខ ១៨៧.២.ប្រក

# ប្រកាស
## ស្តីពីការដាក់តាំង ផ្លាំងយីហោ ផ្លាំងផ្សាយពាណិជ្ជកម្ម ផ្លាំងសញ្ញា

--------

## រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដាឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស /រកម /០១៩៦/០២ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យ លេខ ៦២ អ.ន.ក្រ /ប.ក ចុះថ្ងៃទី ១៤ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញសេចក្តីជូនដំណឹងលេខ ១៣៥ សជណ.សរ ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០០២ ស្តីពីលទ្ធផលសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីនាថ្ងៃទី ១១ ខែមករា ឆ្នាំ២០០២ និងស្មារតីអង្គប្រជុំអន្តរក្រសួង នាទីស្តីការគណៈរដ្ឋមន្ត្រី ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០០២

## សំរេច

ប្រការ ១ :

- ផ្លាំងយីហោ គឺគ្រឿងបង្ហាញ និងសំគាល់នាម របស់អាជីវករ គ្រឹះស្ថាននានា ដែលធ្វើការផលិត ធ្វើសេវាកម្ម ឬធ្វើពាណិជ្ជកម្ម ។

- ផ្ទាំងផ្សាយពាណិជ្ជកម្ម គឺជាគ្រឿង បង្ហាញ និង ផ្សព្វផ្សាយ យីហោ ឬ មុខទំនិញ សំដៅទាក់ទាញអតិថិជន ក្នុងគោលដៅធ្វើអាជីវកម្ម ។
- ផ្ទាំងសញ្ញា គឺជាគ្រឿង សំគាល់ និង បង្ហាញអំពី ព្រឹត្តិការណ៍ ពត៌មាន សកម្មភាព និមិត្តរូប ពេលវេលា ឈ្មោះ ជូនសាធារណជន សំរាប់ ចំណាំ ចងចាំ និង អនុវត្ត ។

ប្រការ ២ :

អំពីរូបភាព ការដាក់តាំងផ្សព្វផ្សាយ និង ការគ្រប់គ្រងត្រួតពិនិត្យ ផ្ទាំងយីហោ ផ្ទាំងផ្សាយ-ពាណិជ្ជកម្ម ផ្ទាំងសញ្ញា ត្រូវសរសេរឱ្យបានត្រឹមត្រូវ តាមពាក្យពេចន៍ និងអក្ខរាវិរុទ្ធជា **អក្សរខ្មែរ** ដោយអនុវត្តតាមវចនានុក្រមរបស់សម្តេចព្រះមហាសុមេធាធិបតីជោតញ្ញាណោ **"ជួន ណាត"** បោះពុម្ពនាឆ្នាំ ១៩៦៧ - ១៩៦៨ ជាមូលដ្ឋាន។

អក្សរខ្មែរត្រូវសរសេរអោយបានធំជាងអក្សរបរទេស ហើយដាក់នៅជួរខាងលើគេបំផុត ។

ប្រការ ៣:

អក្សរបរទេសអាចសរសេរនៅពីខាងក្រោមហើយមានទំហំពាក់កណ្តាលនៃ **អក្សរខ្មែរ** ។ អក្សរបរទេសត្រូវសរសេរអោយបានត្រឹមត្រូវតាមពាក្យពេចន៍ អក្ខរាវិរុទ្ធជាអក្សរបរទេសនិមួយៗ ដើម្បីលើកតម្កើងកិត្យានុភាពជាតិ ។

ប្រការ ៤:

ម្ចាស់ដាក់តាំង និង ផ្សព្វផ្សាយ ផ្ទាំងយីហោ ផ្ទាំងផ្សាយពាណិជ្ជកម្ម ផ្ទាំងសញ្ញា ត្រូវកែលំអឱ្យបានសមស្របតាមប្រកាសនេះ ។

ប្រការ ៥:

រាជធានីភ្នំពេញ ខេត្តសៀមរាប និងក្រុងព្រះសីហនុ ត្រូវអនុវត្តជាបន្ទាន់នូវកិច្ចការនេះឱ្យបានចប់ជាស្ថាពរនៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០០២ ។

ប្រការ ៦:

ខេត្ត-ក្រុង ទូទាំងព្រះរាជាណាចក្រកម្ពុជាដែលពុំមានចែងក្នុងប្រការ៥ ត្រូវអនុវត្តកិច្ចការនេះឱ្យបានចប់ជាស្ថាពរនៅថ្ងៃ ទី៣១ ខែធ្នូ ឆ្នាំ២០០២។

ប្រការ ៧:

មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ ខេត្ត - ក្រុង ទទួលរូបភាព និង ខ្លឹមសារ ត្រូវសហការជាមួយអាជ្ញាធរដែនដី និងអង្គភាព ជំនាញពាក់ព័ន្ធ ដើម្បីអនុវត្តតាមប្រកាសនេះឱ្យទទួលបានលទ្ធផលល្អ។

ប្រការ ៨:

គ្រប់មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្ត-ក្រុង ត្រូវធ្វើរបាយការណ៍ជាទៀងរាល់ខែអំពីលទ្ធផលនៃការអនុវត្តន៍តាមប្រកាសនេះ ផ្ញើមកក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ដើម្បីបូកសរុបរាយការណ៍ជូនរាជរដ្ឋាភិបាល ។

ប្រការ ៩:

ខុទ្ទកាល័យរដ្ឋមន្ត្រី អធិការដ្ឋាន អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌ សាកលវិទ្យាល័យភូមិន្ទ វិចិត្រសិល្បៈ គ្រប់នាយកដ្ឋានក្រោមឱវាទ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងគ្រប់មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត-ក្រុង មានភារកិច្ចអនុវត្តតាមប្រកាសនេះ អោយមានប្រសិទ្ធិភាពខ្ពស់ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៧ខែកក្កដា ឆ្នាំ២០០២

រដ្ឋមន្ត្រី

នរោត្តម - បុប្ផាទេវី

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច នាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង - ស្ថាប័ន
- គ្រប់សាលាខេត្ត-ក្រុង
- ដូចប្រការ៩
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ